លេខ / No: D367

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

លេខសំណុំរឿង: ០០២/១៩-០៩-២០០៧/អ.វ.ត.ក.--ក.ស.ច.ស.

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 02 / 2010
ម៉ោង (Time/Heure): 09:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 02 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

កាលបរិច្ឆេទ ៖ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០

ភាសា ៖ ខ្មែរ/អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

# ដីកាសម្រេចធ្វើការព្រមាន ដោយអនុវត្តតាមវិធាន៣៨

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង
លោក Andrew CAYLEY

**ជនត្រូវចោទ**

នួន ជា
ខៀវ សំផន
អៀង សារី
កាំង ហ្គេកអ៊ាវ ហៅ "ឌុច"
អៀង ធីរិទ្ធ

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

នី ច័ន្ទឌី
ឡោ ជុនធី
គង់ ពិសី
ហុង គីមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ីន សុវ៉ន
ជេត វណ្ណលី
ពេជ អង្គ
Silke STUDZINSKY
Françoise GAUTRY
Isabelle DURAND
Phillipe CANONNE
Elizabeth Rabesandratana
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud
Laure DESFORGES
Christine MARTINEAU

**មេធាវីការពារក្តី**

សុន អរុណ Michiel PESTMAN
Victor KOPPE
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅសៀង Diana ELLIS
ស សុវ៉ាន Jacques VERGÈS
ការ សាវុត្ថ François ROUX
Marie-Paule CANIZARÈS

00478670



យើង យូ ប៊ុនឡេង និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២00៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញវិធាន ៣៥ វិធាន ៣៨ វិធាន ៥៥ និងវិធាន ៥៦ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ("វិធានផ្ទៃក្នុង")

បានឃើញមាត្រា ៣ និងមាត្រា៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")

បានឃើញសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ("សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ")

បានឃើញការស៊ើបសួរ លើឈ្មោះ អៀង សារី និង ជនផ្សេងទៀត ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦

បានឃើញលិខិតឆ្លើយតបរបស់សហចៅក្រស៊ើបអង្កេតទៅនឹងលិខិតចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២00៧ ស្តីពីកិច្ចស៊ើបអង្កេត ចុះថ្ងៃទី ១០ខែមករា ឆ្នាំ ២00៨ (A110/I)

បានឃើញដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងទុកឯកសាររួម (SMD/Shared Materials drive) ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២00៩ (D164/2)

បានឃើញដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធីធ្វើឡើងដោយអៀង ធីរិទ្ធ (D263/1)

បានឃើញលិខិតឆ្លើយឆ្លងដែលបញ្ជូនដោយមេធាវីការពារក្ដីរបស់ អៀង សារី ទៅកាន់ចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការបំពេញកិច្ចស៊ើបសួរដោយខ្លួនឯង ចុះថ្ងៃទី ១0 ខែកុម្ភៈ ឆ្នាំ ២0១0 (D346) ("លិខិតឆ្លើយឆ្លងទាក់ទងនឹងកិច្ចស៊ើបអង្កេត")

បានឃើញលិខិតឆ្លើយឆ្លងដែលបញ្ជូនដោយមេធាវីការពារក្ដីរបស់អៀង សារី ទៅកាន់ចៅក្រមស៊ើបអង្កេត ស្ដីពីការពិនិត្យមើលសំណុំរឿងទាំងមូល ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២0១0 **(D354)** ("លិខិតឆ្លើយឆ្លងស្ដីពីឯកសារសំណុំរឿង")

បានឃើញលិខិតឆ្លើយឆ្លងដែលបញ្ជូនដោយមេធាវីការពារក្ដីរបស់អៀង សារី ទៅកាន់ចៅក្រមស៊ើបអង្កេត ស្ដីពីការចូលរួមក្នុងផ្នែកខ្លះនៃសំណើរបស់ខ្លួនជា ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២0១0 (D355) ("លិខិតឆ្លើយឆ្លងស្ដីពីការចូលរួមក្នុងផ្នែកខ្លះ")

## **ឧត្តិករណ៍ដែលបានលើកឡើងដោយភាគី**

១. សហមេធាវីការពារក្ដីរបស់ អៀង សារី បានដាក់ឯកសារចំនួន 0៣ ច្បាប់ ដែលក្នុងនោះពួកគាត់បានស្នើសហចៅក្រមស៊ើបអង្កេត ដូចខាងក្រោម៖

i) *"បញ្ជាក់ ថាតើសហមេធាវីការពារក្ដី អៀង សារី (សហមេធាវីការពារក្ដី) អាចធ្វើការស៊ើបសួរត្រឹមកម្រិតណាទាក់ទងទៅនឹងសំណុំរឿង 00២"* ដោយបានយោងទៅដល់អនុស្សរណៈមុនរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបញ្ជាក់ថា ភាគីមិនអាចបំពេញកិច្ចស៊ើបសួរដោយខ្លួន

ឯងនោះទេ[1]។ សហមេធាវីការពារក្តីបានលើកឡើងថា ពួកគាត់មានបំណងបំពេញស៊ើបសួរបន្ថែម *"ដោយសារថា ក្នុងចំណោមមូលហេតុផ្សេងទៀត ខ្លួនបាត់បង់ទំនុកចិត្តលើ ក.ស.ច.ស ក្នុងការបំពេញកិច្ចស៊ើបសួរដោយមិនលំអៀង និងឯករាជ្យ"* ដោយអះអាងថាខ្លួនត្រូវបានអនុញ្ញាតឱ្យបំពេញកិច្ចស៊ើបសួរដោយផ្អែកលើការបកស្រាយមាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងដោយផ្អែកលើការបកស្រាយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ស្តីពីការកំណត់ចរិតលក្ខណៈនៃ អ.វ.ត.ក ក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា[2]។

ii) ផ្តល់ការអនុញ្ញាតឱ្យសហមេធាវីការពារក្តី អៀង សារី ពិនិត្យមើល *"សំណុំរឿងទាំងមូល"* (ស្រង់តាមពាក្យដើម) រួមទាំងឯកសារទាំងអស់ដែលជាកម្មសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ដែលភាគីមិនមាន ដូចជាប្រព័ន្ធគ្រប់គ្រងសំណុំរឿង (Casemap) អនុស្សរណៈផ្ទៃក្នុង កំណត់ត្រាស៊ើបអង្កេត ការវិភាគ និងផលិតផលការងារបង្កើតដោយការិយាល័យ សហ ចៅ ក្រម ស៊ើប អង្កេត ទាក់ទងនឹងការស៊ើបសួរក្នុងសំណុំរឿង 00២[3] ។

iii) គាំទ្រ *និងចូលរួមជាផ្នែក "ក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរទី ៩ ដល់សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី២៥ (ដោយរួមបញ្ចូល) របស់នួន ជា "* ដែលក្នុងនោះមានការស្នើសុំសហចៅក្រមស៊ើបអង្កេតផ្តល់នូវព័ត៌មានស្តីអំពី៖ នីតិវិធិស៊ើបសួរដែលបានអនុវត្ត ជាពិសេសទាក់ទងទៅនឹងការប្រមូលភស្តុតាងដោះបន្ទុក ការរៀបចំផែនការ និងយុទ្ធសាស្ត្រស៊ើបសួរក្នុងសំណុំរឿង 00២ និងគុណវុឌ្ឍិ និងបទពិសោធន៍ របស់បុគ្គលិក ក.ស.ច.ស[4]។

## សំអាងហេតុនៃសេចក្តីសម្រេច

២. លិខិតឆ្លើយឆ្លងដែលធ្វើឡើងដោយសហមេធាវីការពារក្តី អៀង សារី បានលើកឡើងបញ្ហាចំនួន

---

[1] D346 ទំព័រទី១ យោង A1 10/I

[2] D346 ទំព័រទី៣យោង សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីបណ្តឹងឧទ្ធរណ៍របស់ឌុចទាក់ទងនឹងឃុំឃាំងបណ្តោះអាសន្ន ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២00៧

[3] D354 ទំព័រទី១

[4] D355 ទំព័រទី១

០៣ ៖ ទី១ ការមិនគោរពវិធានស្តីពីការដាក់ឯកសារ ទី២ ការមិនគោរពវិធាននីតិវិធិដែលត្រូវអនុវត្ត ក្នុងដំណើរការនៃការស៊ើបសួរ និងទី៣ ការដាក់ឯកសារត្រួតគ្នា និងការលើកឡើងអំពីបញ្ហាច្រំដែល ដែលត្រូវបានដោះស្រាយតាមផ្លូវតុលាការរួចមកហើយ។

*ការមិនគោរពវិធានស្តីពីការដាក់ឯកសារ*

៣. លិខិតឆ្លើយឆ្លងចំនួន៣របស់សហមេធាវីការពារក្តីបានថ្លែងថា ឯកសារទាំងនោះត្រូវដាក់ជាសាធារណៈ។ អនុលោមតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ និងសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារ ភាគីគ្រាន់តែអាចស្នើឱ្យចាត់ប្រភេទឯកសារ ដែលពួកគាត់ដាក់ជូនទៅសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ[5]។ វាមិនមែនជាលើកដំបូងទេ ដែលក្រុមមេធាវីការពារក្តី អៀង សារី ត្រូវបានរំលឹកអំពីនីតិវិធីនេះ[6]។

៤. ដូច្នេះ អនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតធ្វើការព្រមានដល់សហមេធាវីការពារក្តី អៀង សារី ថា ពួកគេត្រូវបញ្ជាក់នៅលើឯកសារឱ្យបានច្បាស់ថា ការកំណត់ប្រភេទឯកសារដែលធ្វើឡើងដោយភាគីគ្រាន់តែជាសំណើតែប៉ុណ្ណោះ ។ ទាំងនេះវាមានលក្ខណៈគ្រប់គ្រាន់ ដោយផ្អែកទៅលើខ្លឹមសារនៃឧបសម្ព័ន្ធ "ខ" នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ដែលមានឈ្មោះថា "ប្រភេទឯកសារដែលស្នើដោយភាគីដាក់ឯកសារ"[7]។

៥. ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតធ្វើការព្រមានសហមេធាវី អៀង សារី ថាការដាក់ឯកសារបន្ថែមណាមួយ ដែលមិនមានបញ្ជាក់អំពីប្រភេទនៃចំណាត់ថ្នាក់ឯកសារ វាគ្រាន់តែជាសំណើសុំប៉ុណ្ណោះ ហើយការផ្សព្វផ្សាយព័ត៌មានជាសាធារណៈណាមួយ ដែលទាក់ទិននឹងការដាក់ឯកសារមុននឹងមានការធ្វើចំណាត់ថ្នាក់ប្រភេទឯកសារនេះថាជាឯកសារសាធារណៈ ដោយសហចៅក្រមស៊ើប

---

[5] មាត្រា ៣ (២) (ក), ៣ (១២), ៣ (១៣) សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ សូមមើលសេក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង

[6] សូមមើលឧទាហរណ៍៖ A238/1; D138, D138/1/8

[7] សូមមើល D163.5 ក្រឡាបញ្ជីប្រគល់ឯកសារដែលដាក់មិនមានលក្ខណៈគ្រប់គ្រាន់ ដែលមិនស្របនឹងសេចក្តីចែងក្នុងសេចក្តីបន្ថែមនៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ

00478674



អង្កេត វារីតតែខុសឆ្គងថែមទៀត ហេតុដូច្នេះ សហមេធាវីត្រូវបានព្រមាននៅក្នុងដីកានេះ ស្របទៅតាមវិធាន៣៨ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ដែលចែងថា ទណ្ឌកម្មអាចត្រូវបានអនុវត្តចំពោះពួកគេ។

*ការមិនគោរពវិធាននីតិវិធីដែលត្រូវអនុវត្តក្នុងដំណើរការនៃការស៊ើបសួរ*

៦. លិខិតឆ្លើយឆ្លងទាក់ទិននឹងការស្នើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង សារី បានយោងទៅលើមាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចំណងជើង "ការសម្ងាត់នៃការស៊ើបសួរ" ដែលចែងថា ៖

> *បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និង បុគ្គលិកដែលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ។*

៧. សហមេធាវីការពារក្តី អៀង សារី ធ្វើការសន្និដ្ឋានថា "មាត្រា ១២១ អនុញ្ញាតឱ្យមានការចូលរួមរបស់មេធាវីនៅក្នុងការស៊ើបសួរ ប្រសិនបើការសម្ងាត់នៃការស៊ើបសួរត្រូវបានរក្សា"។ ប្រសិនបើបុគ្គលណាចាត់ទុកថា ការលើកហេតុផលរបស់សហមេធាវីការពារក្តី អៀង សារី ជាសេចក្តីសន្និដ្ឋានសមហេតុសមផលនោះ ក្រឡាបញ្ជី មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែផ្ទាល់មាត់/ឯកសារ វេជ្ជបណ្ឌិត និងបុគ្គលដទៃ ដែលមានឈ្មោះនៅក្នុងមាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏អាចធ្វើការស៊ើបសួរបានដែរ ឱ្យតែពួកគេរក្សាការសម្ងាត់បាន។ លើសពីនេះទៅទៀត នគរបាលយុត្តិធម៌ និងកងរាជអាវុធហត្ថ ក៏អាចធ្វើបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងដែរ ដោយមិនចាំបាច់គោរពមាត្រា ៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតម្រូវឱ្យនគរបាលយុត្តិធម៌ និងកងរាជអាវុធហត្ថអាចបំពេញកិច្ចស៊ើបសួរដោយផ្អែកទៅលើដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះ។ វាច្បាស់ណាស់ថា ការបកស្រាយបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌនេះមានលក្ខណៈមិនត្រឹមត្រូវទេ ។

៨. សហចៅក្រមស៊ើបអង្កេតយល់ច្បាស់ណាស់ថាណ សហមេធាវីការពារក្តី អៀង សារី ព្យាយាមសំអាងសំណើបំពេញកិច្ចស៊ើបសួររបស់ខ្លួន តាមរយៈការច្រានចោលមិនអនុវត្តប្រព័ន្ធច្បាប់ Civil

Law ដែលក្នុងនោះ ដំណើរការនៃកិច្ចស៊ើបសួរត្រូវធ្វើឡើងដោយចៅក្រមស៊ើបអង្កេតតែមួយគត់[8]។ តាមពិត សហមេធាវីការពារក្តី អៀង សារី បានយោងទៅលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៨ ដែលក្នុងនោះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់អះអាងជាច្រើនសារមកហើយថា ៖

*"នៅចំពោះមុខតុលាការនេះ អំណាចក្នុងការដឹកនាំកិច្ចស៊ើបសួរត្រូវបានផ្តល់ឱ្យតែចៅក្រមស៊ើបអង្កេតឯករាជ្យ មិនផ្តល់ឱ្យភាគីទេ។ មិនមានបទប្បញ្ញត្តិណាដែលអនុញ្ញាតឱ្យភាគីដំណើរការកិច្ចស៊ើបសួរ ជំនួសសហចៅក្រមស៊ើបអង្កេត ដូចដែលមាននៅក្នុងប្រព័ន្ធនីតិវិធីផ្សេងនោះទេ។ ជាការពិតអនុលោមតាមវិធាន ៥៥(១០) និង ៥៨(៦) ភាគីនានាមានសិទ្ធិស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតឱ្យបំពេញកិច្ចស៊ើបសួរបាន ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនទទួលយកសំណើនោះទេ ខ្លួនត្រូវចេញដីកាសម្រេចបដិសេធសំណើនោះ យ៉ាងយូរបំផុតឱ្យបានមុខបញ្ចប់កិច្ចស៊ើបសួរ ហើយដីកាសម្រេចនេះបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍បាន។ ហេតុនេះ សមត្ថភាពរបស់ភាគីក្នុងការធ្វើអន្តរាគមន៍មានកម្រិតត្រឹមតែសំណើដើមដំបូងប៉ុណ្ណោះ ដែលជាការចាំបាច់សម្រាប់អនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរ[9]"។*

៩. ហេតុដូច្នេះ អនុវត្តតាមវិធាន៣៨នៃវិធានផ្ទៃ សហចៅក្រមស៊ើបអង្កេតធ្វើការព្រមានសហមេធាវីការពារក្តី អៀង សារី ថា ពួកគេត្រូវបានហាមឃាត់មិនឱ្យបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងទេ ហើយការបំពានទៅលើការហាមឃាត់នេះនឹងប្រឈមមុខនឹងការដាក់ទណ្ឌកម្ម។

*ការដាក់ឯកសារត្រួតគ្នា និងការលើកឡើងអំពីបញ្ហាចំដែល ដែលត្រូវបានដោះស្រាយតាមផ្លូវតុលាការរួចមកហើយ*

១០. សំណើសុំចំនួនបីរបស់សហមេធាវីការពារក្តី អៀង សារី បានលើកឡើងនូវបញ្ហានានាជាច្រើន

---

[8] សហចៅក្រមស៊ើបអង្កេត បានធ្វើការសង្កេតស្រដៀងគ្នាលើការដាក់ឯកសារទាក់ទងនឹងសហមេធាវីការពារក្តីនួន ជា ដែលទោះជាវាបានឆ្លើយតបនឹងទិដ្ឋភាពទាក់ទងទៅនឹងការដាក់ឯកសារដោយសហមេធាវីការពារក្តីអៀង សារី ដែលសហមេធាវីការពារក្តីអៀង សារី ត្រូវបានជូនដំណឹងដោយសមស្របក៏ដោយ (សហចៅក្រមស៊ើបអង្កេតបានចាត់ប្រភេទវាជាឯកសាធារណៈ:) D22/1/1 ទំព័រទី១

[9] A110/I ទំព័រទី២

ដែលត្រូវបានធ្វើឡើងរួចមកហើយ និងថែមទាំងបានដោះស្រាយរួចរាល់អស់ហើយដែរ នៅក្នុងដំណាក់កាលនានានៃដំណើរការនីតិវិធី ដូចជា៖

ក) ជាការពិត ដូចអ្វីដែលសហមេធាវីការពារក្តី អៀង សារី បានលើកឡើងនៅក្នុងសំណើលេខ D346 បញ្ហាដែលបានពិចារណាខាងលើ ថាតើភាគីនានាអាចបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងបានទេ ត្រូវបានលើកឡើងរួចមកហើយដោយភាគីនានា ហើយក៏ត្រូវបានដោះស្រាយដោយសហចៅក្រមស៊ើបអង្កេតដែរ[10]។

ខ) ជាថ្មីម្តងទៀត ដូចដែលសហមេធាវីការពារក្តី អៀង សារី បានធ្វើការកត់សម្គាល់នៅក្នុងសំណើ D354[11] សហចៅក្រមស៊ើបអង្កេតបានធ្វើការឆ្លើយតបរួចហើយចំពោះសំណើរបស់លោក អៀង សារី សុំចូលមើលព័ត៌មានដែល "ពាក់ព័ន្ធ"។

គ) លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតក៏បានឆ្លើយតបរួចហើយចំពោះបញ្ហានានា ដែលបានលើកឡើងនៅក្នុងសំណើលេខ D355 តាមរយៈលិខិតឆ្លើយតបរបស់ខ្លួនចំពោះសហមេធាវីការពារក្តី អៀង សារី, នួន ជា និង ខៀវ សំផន ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ (ឯកសារលេខ D171/5)។

១១. សហមេធាវីការពារក្តីលោក អៀង សារី ក៏និយាយរៀបរាប់ការចោទប្រកាន់ដដែលៗ ដូចពីមុនៗនៅក្នុងលិខិតចំនួនបីរបស់កាលពីពេលមុន ទាក់ទិននឹង "ការខ្វះទំនុកចិត្តរបស់ខ្លួន" ចំពោះសហចៅក្រមស៊ើបអង្កេត និងបុគ្គលិកដែលនៅក្រោមឱវាទ[12]។ បញ្ហានេះក៏ត្រូវបានដោះស្រាយរួចហើយដោយសហចៅក្រមស៊ើបអង្កេត និង ត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះផងដែរ[13]។

១២. វិធានផ្ទៃក្នុងនៃ អ.វ.ត.ក ក៏បានចែងអំពីបញ្ហានានា ដែលអាចអនុញ្ញាតឲ្យប្តឹងធ្វើឧទ្ធរណ៍បាន

---

[10] ឯកសារលេខ A110/I។ សូមមើលផងដែរ ឯកសារលេខ D1264/2 កថាខណ្ឌ១៤។

[11] សូមមើលឯកសារលេខ D354 កថាខណ្ឌ៣៖ "*ក្នុងការបដិសេធសំណើពីមុនសុំពិនិត្យព័ត៌មានដែលពាក់ព័ន្ធ សហចៅក្រមស៊ើបអង្កេតផ្អែកទៅលើវិធាន៧០(ក) នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់តុលាការ ICTY*"។

[12] ឯកសារលេខ D346 ទំព័រ ១-២, ឯកសារលេខ D354 ទំព័រ ១-២, ឯកសារលេខ D355 ទំព័រ ១-៤។

[13] សូមមើល ការដាក់ឯកសារនិងសេចក្តីសម្រេចទាក់ទឹងនឹងឯកសារលេខ A121, A162, a252, D171, D221, D263, D264។ ដូចបានអនុវត្តជាធម្មតាមកហើយ ក្នុងការរក្សាសំណុំរឿង សហមេធាវីការពារក្តីលោក អៀង សារី ត្រូវបានទទួលការកត់សម្គាល់ ចំពោះការឯកសារសម្ងាត់ និង សាធារណៈ និង សេចក្តីសម្រេចនានា ទោះបីពួកគេមិនទទួលខុសត្រូវដោយខ្លួនឯងក្នុងការដាក់ឯកសារដើមដំបូង។

00478677



និងអំពីនីតិវិធីក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ រួមទាំងលក្ខខណ្ឌថាតើបណ្តឹងឧទ្ធរណ៍នោះអាចទទួលយកបានដែរ ឬទេ[14]។ ភាគីនានាមិនអាចប៉ុនប៉ងមិនអនុវត្តវិធាននេះ ដោយធ្វើការដាក់សំណើសុំលើបញ្ហាដដែលៗ ដែលត្រូវបានដោះស្រាយតាមផ្លូវតុលាការរួចមកហើយនោះទេ។

១៣. សហចៅក្រមស៊ើបអង្កេតបានរំលឹកភាគីអំពីស្ថានភាពពិសេសដែល អ.វ.ត.ក កំពុងប្រឈម។ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយមិនមានការពន្យារពេលមិនសមហេតុផល គឺជាចំណុចស្នូលនៃសិទ្ធិក្នុងទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ស្ថានភាពអាយុ និងស្ថានភាពសុខភាពរបស់ជនត្រូវចោទកាន់តែជម្រុញឲ្យភាគីទាំងអស់ បំពេញការងារឲ្យកាន់តែមានប្រសិទ្ធិភាព តាមដែលអាចធ្វើបាន។ វាជាប្រយោជន៍របស់តុលាការដែលត្រូវសន្សំសំចៃ និងមិនខ្ជះខ្ជាយធានធានរបស់ខ្លួនដោយឥតប្រយោជន៍[15]។

១៤. ដោយអនុវត្តតាមវិធាន៣៨ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីព្រមានជាច្រើនលើកច្រើនសារទៅដល់ភាគី ជាពិសេសនៅក្នុងចម្លើយតបចំពោះសំណើសុំរបស់សហមេធាវីការពារក្តី អៀង សារី ទាក់ទិននឹងការដាក់សំណើសុំច្រំដែល[16]។ នៅក្នុងសំណើសុំក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ខ្លឹមសារនិងទំហំនៃភាពច្រំដែល គឺជាការរំលោភនិតិវិធី។ ហេតុដូច្នេះ អនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតព្រមានសហមេធាវីការពារក្តី អៀង សារី ថា ពួកគេត្រូវបានហាមឃាត់ដាច់ខាត មិនឲ្យដាក់សំណើសុំច្រំដែល ឬដាក់សំណើសុំជំទាស់នឹងបញ្ហាទាំងឡាយដែលបានដោះស្រាយដោយបណ្តឹងឧទ្ធរណ៍រួចហើយ ហើយថាប្រសិនបើមានការបំពានលើការហាមឃាត់នេះ ពួកគេនឹងប្រឈមមុខនឹងការដាក់ទណ្ឌកម្ម។

១៥. ប្រសិនបើមានការដាក់សំណើច្រំដែល ឬការដាក់សំណើសុំផ្សេងទៀតដែលរំលោភទៅលើដីកានេះ នៅពេលអនាគត ដោយ អៀង សារី ឬដោយភាគីផ្សេងទៀត រួមទាំងបញ្ហាដែលបានដោះស្រាយរួចហើយតាមរយៈបណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតនឹងបដិសេធសំណើទាំងនោះយ៉ាងខ្លីដោយយោងទៅលើសេចក្តីសម្រេច និងសំណើសុំដែលបានដាក់ពីមុនមកទៅតាមការចាំបាច់។

---

14 សូមមើលឧទាហរណ៍របស់ វិធាន៥៥(១០) នៃ វិធានផ្ទៃក្នុង សម្រាប់ការប្តឹងឧទ្ធរណ៍នៃសំណើសុំបើកកិច្ចស៊ើបសួរ។

15 ឯកសារលេខ D261/2 កថាខណ្ឌ ១៣-១៤។

16 ឯកសារលេខ D240/3 កថាខណ្ឌ ៦, ឯកសារលេខ D261/2 កថាខណ្ឌ ១៣-១៤។

## អាស្រ័យហេតុនេះ

- **សម្រេច** បង្គាប់ឲ្យសហមេធាវីការពារក្តី អៀង សារី គោរពតាមសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារ (រួមទាំងឧបសម្ព័ន្ធ "ខ") និងសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារដែលបានកំណត់ថា "ប្រភេទឯកសារដែលស្នើដោយភាគីដាក់ឯកសារ"។

- **បង្គាប់ឲ្យ** សហមេធាវីការពារក្តី អៀង សារី គោរពតាមចំណាត់ថ្នាក់ឯកសារដែលសម្រេចដោយសហចៅក្រមស៊ើបអង្កេត។

- **ព្រមាន** សហមេធាវីការពារក្តី អៀង សារី នៅក្រោមបញ្ញត្តិនៃវិធាន ៣៨ នៃវិធានផ្ទៃក្នុងថា ការរំលោភលើសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារ និងសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ថ្នាក់ឯកសារ នឹងនាំទៅដល់ការដាក់ទណ្ឌកម្មដោយសហចៅក្រមស៊ើបអង្កេត ដោយអនុវត្តវិធាន ៣៨ នៃវិធានផ្ទៃក្នុង។

- **ព្រមាន** សហមេធាវីការពារក្តី អៀង សារី នៅក្រោមបញ្ញត្តិនៃវិធាន ៣៨ នៃវិធានផ្ទៃក្នុងថា ពួកគេត្រូវបានហាមឃាត់មិនឲ្យដាក់សំណើសុំច្រំដែល ឬធ្វើសំណើសុំជំទាស់ទៅនឹងបញ្ហានានាដែលត្រូវបានដោះស្រាយរួចហើយតាមរយៈបណ្តឹងឧទ្ធរណ៍ ហើយការបំពានលើការហាមឃាត់នេះ នឹងនាំទៅដល់ការសម្រេចដាក់ទណ្ឌកម្ម ។

- **ព្រមាន** សហមេធាវីការពារក្តី អៀង សារី នៅក្រោមបញ្ញត្តិនៃវិធាន ៣៨ នៃវិធានផ្ទៃក្នុងថា ពួកគេត្រូវបានហាមឃាត់មិនឲ្យបំពេញកិច្ចស៊ើបសួរដោយខ្លួនឯង ហើយការបំពានលើការហាមឃាត់នេះ នឹងនាំទៅដល់ការសម្រេចដាក់ទណ្ឌកម្ម ។

- **បដិសេធ** សំណើសុំទាំងបីរបស់សហមេធាវីការពារក្តី អៀង សារី (ឯកសារលេខ D346, D354, D355) ។

- **កត់សម្គាល់** ថាភាគីទាំងអស់នឹងទទួលបានដីកានេះ ដូច្នេះពួកគេទទួលត្រូវបានដាស់តឿនជាមុន និងត្រូវបានព្រមានថា ពួកគេត្រូវតែអនុវត្តតាមសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារ (រួមទាំងឧបសម្ព័ន្ធ "ខ") ក៏ដូចជាសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ ដោយមានបញ្ជាក់ថា "ប្រភេទឯកសារដែលស្នើដោយភាគីដាក់ឯកសារ" ព្រមទាំងចំណាត់ថ្នាក់ឯកសារ

ដែលបានសម្រេចដោយសហចៅក្រមស៊ើបអង្កេតថាពួកគេមិនអាចដាក់ឯកសាររួមគ្នា ហើយថាពួកគេត្រូវបានហាមឃាត់មិនឲ្យដឹកនាំកិច្ចស៊ើបសួរដោយខ្លួនឯង ។

- **ប្រកាស** ថាក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត នឹងបញ្ជូនឲ្យភាគីដែលដាក់ឯកសារវិញនូវឯកសារណាដែលបំពានដល់សេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារ និង ឧបសម្ព័ន្ធនានា និង សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ថ្នាក់ឯកសារ ដោយមិនបញ្ចូលក្នុងសំណុំរឿងឡើយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

យូ ប៊ុនឡេង

**Marcel LEMONDE**